Government of South Australia
Department for Education

**Office of the Chief Executive**
31 Flinders Street
Adelaide SA 5000
GPO Box 1152
Adelaide SA 5001
DX 541
www.education.sa.gov.au

ជម្រាបមកដល់មាតាបិតានិងអ្នកថែទាំ

COVID-19 បានផ្តល់ការលំបាកគ្រប់ប្រភេទទាំងអស់សម្រាប់យើង ក្នុងភាពជាបុគ្គល គ្រួសារ និងសហគមន៍។

យើងមានមោទកភាពក្នុងការនិយាយថា គ្រូបង្រៀននិងបុគ្គលិកជំនួយរបស់យើងបានបំពេញការងារបានល្អប្រសើរនៅក្នុងស្ថានការណ៍នេះ។ ទោះជាពួកគាត់ប្រហែលជាមានភាពរសាប់រសល់ក្នុងភាពជាសមាជិកសហគមន៍ក្តី ក៏ពួកគាត់កំពុងបន្តដាក់ការសិក្សារបស់សិស្សថាជាបញ្ហាសំខាន់ជាងគេដែរ។

សាលារៀននិងមត្តេយ្យសាលាជាសេវាដ៏សំខាន់ក្រៃលែងមួយ។ ដំបូន្មានសុខភាពសាធារណៈពីអ្នកឯកទេសជាន់ខ្ពស់នៅពាសពេញអូស្ត្រាលីនៅតែនិយាយថា សាលារៀននិងមត្តេយ្យសាលាអាចនិងគួរតែរក្សាការសិក្សា។

យើងនឹងបន្តទទួលការណែនាំដោយដំបូន្មានសុខភាព និងអនុសាសន៍របស់គេអំពីការរក្សាចម្ងាយក្នុងសង្គម និងការអនុវត្តថែរក្សាអនាម័យនៅក្នុងថ្នាក់រៀននិងកន្លែងលេង។ សុវត្ថិភាពនិងសុខុមាលភាពរបស់សិស្ស បុគ្គលិក និងសហគមន៍សាលារៀនរបស់យើងគឺជាអាទិភាពកំពូលមួយនៅពេលដែលយើងផ្តល់ការសិក្សាដែលមានគុណភាពខ្ពស់តទៅទៀត។

នៅក្នុងពេលដែលពលរដ្ឋជាច្រើនកំពុងស្នាក់នៅក្នុងផ្ទះដើម្បីជួយបញ្ឈប់ការរាលដាលនៃ COVID-19 យើងនឹងមិនឈរនៅស្ងៀមឡើយ។

ការបន្តការសិក្សាសម្រាប់កុមារនិងជនវ័យក្មេងរបស់យើងនៅក្នុងរដ្ឋនេះ នៅតែជាការយកចិត្តទុកដាក់ស្នូលរបស់យើង។ គ្រូបង្រៀន អ្នកអប់រំកុមារភាពក្មេងខ្ចី នាយកសាលា និងបុគ្គលិកក្រសួង កំពុងផ្លាស់ប្តូរជាប់រហូតនូវសំណើផ្តល់របស់យើង ដើម្បីគាំទ្រគ្រួសារនិងអ្នកថែទាំទាំងឡាយនៅក្នុងខណៈដែលមិនធ្លាប់មានពីមុនទាំងនេះ។

កាលពីអាទិត្យមុន យើងបានផ្តើមឲ្យមាន Our Learning SA (ការសិក្សា SA របស់យើង) ជាវិបសៃមួយដែលផ្ទុកធនធានបង្រៀនរាប់រយដើម្បីជួយកុមារនិងជនវ័យក្មេងក្នុងការតាមឲ្យទាន់នូវការសិក្សារបស់ខ្លួន នៅពេលគេស្នាក់នៅផ្ទះ។ មានរួមបញ្ចូលដែរនោះគឺការតភ្ជាប់ទៅកាន់កម្មវិធី ABC TV ដែលមានគុណភាពខ្ពស់ ហើយអាចជួយដល់ការសិក្សារបស់សិស្សផងដែរ។ វិបសៃនេះនឹងរីកលូតលាស់តទៅទៀត ហេតុនេះសូមឆែកមើលវានៅឯ www.ourlearning.sa.edu.au។

យើងក៏បានបង្កើតផ្នែកដំបូន្មានសម្រាប់គ្រួសារមួយនៅតាមវិបសៃនេះផងដែរ ដែលមានវីដេអូនិងបណ្ណអង្គហេតុសម្រាប់សិស្សនិងគ្រួសារ ដោយមានរួមទាំង៖

- ការបង្កើតមជ្ឈដ្ឋានសិក្សាមួយ
- ការរក្សាសេចក្តីសប្បាយរីករាយនិងមានសុខភាពល្អនៅក្នុងពេលសិក្សានៅផ្ទះ
- ការអាននៅផ្ទះជាមួយនឹងកូនលោកអ្នក

- ការរៀបចំសម្រាប់ការសិក្សាតាមអនឡាញ
- ការនិយាយទៅកាន់កូនលោកអ្នកអំពី COVID-19

សាលារៀននិងមត្តេយ្យសាលាស្ថិតនៅដំណាក់កាលផ្សេងៗគ្នានៅក្នុងការអនុវត្តការរៀបចំសិក្សាពីចម្ងាយ។ បន្ថែមទៅទៀតនោះ យើងដឹងថា មិនមែនកុមាររាល់រូបមានកុំព្យូទ័រឬមានអ៊ីនធើរណិតនៅផ្ទះឡើយ។

នៅអាទិត្យនេះ ក្នុងអំឡុងពេលសិស្សឈប់សម្រាកបួនថ្ងៃ គ្រូបង្រៀនរបស់យើងនឹងចាប់យកការសិក្សានៅផ្ទះទៅកាន់កម្រិតបន្ទាប់ទៀត។

យើងនឹងធ្វើឲ្យ virtual classrooms (ថ្នាក់រៀនតាមអនឡាញដែលធ្វើប្រតិកម្មទៅវិញទៅមក)មានដំណើរការសម្រាប់គ្រូបង្រៀនគ្រប់រូប ហើយនឹងពិនិត្យរកមើលវិធីដើម្បីឲ្យសិស្សដែលគ្មានកុំព្យូទ័រឬអ៊ីនធើរណិតផ្សាភ្ជាប់នឹងថ្នាក់រៀនរបស់ខ្លួន។ វិធីនេះធ្វើទៅជាមួយគ្នានឹងធនធានឯកសារដែលគ្រូបង្រៀនបានជាប់រវល់រៀបចំសម្រាប់សិស្សដែលត្រូវការឯកសារទាំងនោះ។

យើងមានចំណាប់អារម្មណ៍តទៅទៀតជាមួយនឹងរបៀបដែលបុគ្គលិកនិងគ្រូបង្រៀនរបស់យើងកំពុងសហការគ្នាដើម្បីរៀបចំសម្រាប់ត្រីមាសទី 2។ យើងទាំងអស់ស្ថិតក្នុងស្ថានការណ៍នេះទាំងអស់គ្នា។

សូមធ្វើការជាមួយគ្រូបង្រៀនរបស់កូនលោកអ្នក បើលោកអ្នកត្រូវការជំនួយបន្ថែម ឬមានសំណួរណាមួយ។

ដោយក្តីគោរពស្មោះស្ម័គ្រ

Hon John Gardner MP
**រដ្ឋមន្ត្រីអប់រំ**

7 មេសា 2020

Rick Persse
**នាយកប្រតិបត្តិ**

7 មេសា 2020